**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៦២ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ឯកសណ្ឋានការងារ និងសញ្ញាសក្តិសម្រាប់សម្គាល់មេឃុំ ចៅសង្កាត់ ជំនប់ ចៅសង្កាត់រង និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់

បណ្ណាគារ ភក្តីឡ
PheakdeyLaw Book Store

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៤ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

www.pheakdeylaw.com

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.—**

ត្រូវបានបង្កើតឯកសណ្ឋានការងារ និងសញ្ញាស័ក្តិសម្រាប់សម្គាល់មេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ។

**មាត្រា ២.—**

ឯកសណ្ឋាន និងសញ្ញាស័ក្តិនេះ ត្រូវបានឲ្យប្រើប្រាស់សម្រាប់ពេលបំពេញការងារ និងនៅពេលចូលរួមពិធីផ្លូវការនានា ។

## ជំពូកទី២

## សញ្ញាស័ក្តិ

**មាត្រា ៣.—**

សញ្ញាស័ក្តិសម្រាប់សម្គាល់មេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានកំណត់ ដូចខាងក្រោម:

**១- ចំពោះមេឃុំ ចៅសង្កាត់**

ជាស័ក្តិសម្រាប់ពាក់លើស្មា មានផ្ទៃកម្ទីពណ៌ខ្មៅ រចនាគុបតែងដោយក្បាច់គូរស្រូវពណ៌មាស និងក្បាច់សន្លឹកភ្ញីទេសពណ៌មាស ដាក់ខ្វែងគ្នានៅផ្នែកខាងក្រោមនៃតួស័ក្តិ។ នៅផ្នែកខាងលើ មានរូបសាលាឃុំពណ៌មាស។ នៅខាងលើរូបសាលាឃុំ មានទ្បេវពណ៌មាសមួយរូបព្រះរាជសង្ហារពណ៌មាស បន្ទាប់មកមានបន្ទះក្បាច់ផ្ចេញក្របីពណ៌មាសព័ទ្ធជុំវិញហាន ។ ផ្ទៃខាងក្រៅ នៃក្បាច់ផ្ចេញក្របីនេះ មានក្បាច់ខ្សែពួរវេញពណ៌មាស ព័ទ្ធជុំវិញបីជាន់ ។

**២- ចំពោះជំទប់ ចៅសង្កាត់រង និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់**

ជាស័ក្តិសម្រាប់ពាក់លើស្មា មានផ្ទៃកម្ទីពណ៌ខ្មៅ រចនាគុបតែងដោយក្បាច់គូរស្រូវពណ៌ប្រាក់ និងក្បាច់សន្លឹកភ្ញីទេសពណ៌ប្រាក់ ដាក់ខ្វែងគ្នានៅផ្នែកខាងក្រោមតួស័ក្តិ ។ នៅផ្នែកខាងលើ មានរូបសាលាឃុំពណ៌ប្រាក់ ។ នៅខាងលើរូបសាលាឃុំ មានទ្បេវពណ៌ប្រាក់មួយរូបព្រះរាជសង្ហារពណ៌ប្រាក់ បន្ទាប់មកមានបន្ទះក្បាច់ផ្ចេញក្របីពណ៌ប្រាក់ ព័ទ្ធជុំវិញហាន ។ ផ្ទៃខាងក្រៅ នៃក្បាច់ផ្ចេញក្របីនេះ មានក្បាច់ខ្សែពួរវេញពណ៌ប្រាក់ ព័ទ្ធជុំវិញ ដែលក្នុងនោះ ៖

- ពីរជាន់ សម្រាប់សម្គាល់មុខតំណែងជំទប់ ចៅសង្កាត់រង
- មួយជាន់ សម្រាប់សម្គាល់មុខតំណែងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ។

**ខ្នាតស័ក្តិ ត្រូវបានកំណត់ ដូចខាងក្រោម ៖**

- បាតក្រោមប្រវែង ០៦ សង្ទីម៉ែត្រ

www.pheakdeylaw.com

- ទទឹងមុខកាត់ខាងលើប្រវែង ៤,៥០ សង្ទីម៉ែត្រ មានរាងកោងជាមុំទាល
- បណ្តោយពីលើដល់បាតក្រោមប្រវែង ១៣ សង្ទីម៉ែត្រ

រូបសញ្ញាស័ក្តិ សម្រាប់សម្គាល់មេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់មានគំរូដូចក្នុងឧបសម្ព័ន្ធទី១ នៃអនុក្រឹត្យនេះ ។

## ជំពូកទី៣
## ប្រភេទឯកសណ្ឋាន និងការប្រើប្រាស់

**មាត្រា ៤.—**

ប្រភេទឯកសណ្ឋានសម្រាប់សម្គាល់មេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានកំណត់ ដូចខាងក្រោម ៖

**១ - ចំពោះបុរស**

- អាវសឺមិ កឧប បើកក ដៃវែងឬ ដៃខ្លីពណ៌កាគី មានប៉ូលស្មាសងខាង មានហោប៉ៅលើពីរ ដេរប៉ះ បត់ផ្នត់កណ្តាល មានគម្របរាងស្លឹកពោធិ៍នៅខាងលើ ។ ហោប៉ៅនីមួយៗ មានឡេវបញ្ឆោត ពណ៌កាគី ។ អាវនេះ មានឡេវខាងមុខពណ៌កាគី ០៧ គ្រាប់ ។
- ខោជើងវែងពណ៌កាគី ថ្នេរបង្កប់ ចង្កេះត មានហោប៉ៅបួន ដោយហោប៉ៅខាងក្រោយពីរដេរបង្កប់ មានគម្របស្លឹកពោធិ៍ និងចំហៀងពីរដេរបង្កប់តាមថ្នេរ ។
- នៅផ្នែកខាងមុខមានក្លីពីរ សងខាង ។
- ស្លាកឈ្មោះសម្រាប់ពាក់នៅលើហោប៉ៅខាងស្តាំ មានរាងបួនជ្រុងទ្រវែង ដែលមានបណ្តោយប្រវែង ១០ សង្ទីម៉ែត្រ និងទទឹងប្រវែង ២,៥០ សង្ទីម៉ែត្រ ធ្វើអំពីជ័ររឹងថ្លា ផ្ទៃពណ៌ខៀវចាស់ និងមានខ្សែបន្ទាត់ពណ៌មាសទំហំ ០,២៥ សង្ទីម៉ែត្រព័ទ្ធជុំវិញ ។ នៅជួរខាងលើ មានសរសេរនាមត្រកូល និងនាមខ្លួនជាភាសាខ្មែរ ប្រភេទអក្សរមូលពណ៌មាសទំហំ ៣៣ និងជួរខាងក្រោមមានសរសេរមុខតំណែងជាភាសាខ្មែរ ប្រភេទអក្សរមូលពណ៌មាសទំហំ ២៧ ។
- ស្បែកជើងឃ្លុប កខ្លី ពណ៌ខ្មៅ មានចងខ្សែ និងស្រោមជើងពណ៌ខ្មៅ ។

**២ - ចំពោះនារី**

- អាវសឺមិ កឧប បើកក ដៃវែង ឬដៃខ្លី ពណ៌កាគីមានសណ្ឋានដូចអាវបុរសដែរ ។
- សំពត់ហ្សីបបត់ពណ៌កាគី មានសម្រុងលើភ្នែកគោល នៃស្មងជើងប្រវែងពី ១០ ទៅ ១៥ សង្ទីម៉ែត្រ អនុលោមទៅតាមមាឌ និងកំពស់ ។
- ស្លាកឈ្មោះសម្រាប់ពាក់នៅលើហោប៉ៅខាងស្តាំ មានភិនភាគដូចស្លាកឈ្មោះរបស់បុរសដែរ ។
- ស្បែកជើង ឃ្លុបមុខក្រោយ ពណ៌ខ្មៅ មានកែងធម្មតា ។

www.pheakdeylaw.com

រូបឯកសណ្ឋានសម្លៀកបំពាក់ សម្រាប់សម្គាល់មេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ មានរូបគំរូដូចក្នុងឧបសម្ព័ន្ធទី២ នៃអនុក្រឹត្យនេះ។

**មាត្រា ៥ .—**

ប្រភេទឯកសណ្ឋាន សម្រាប់សម្គាល់មេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបានអនុញ្ញាតឲ្យសាមីជនប្រើប្រាស់តែក្នុងអាណត្តិប៉ុណ្ណោះ ។

## ជំពូកទី៤

## អវសានប្បញ្ញត្តិ

**មាត្រា ៦ .—**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៧ .—**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ អភិបាល នៃគណៈអភិបាលគ្រប់ខេត្ត មេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង និងសមាជិកក្រុមប្រឹក្សាគ្រប់ឃុំ សង្កាត់ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះ ហត្ថលេខា តទៅ ។

បណ្ណាគារ ភក្តីឌី
PheakdeyLaw Book Store

រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែមេសា ឆ្នាំ២០១១

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**<u>កន្លែងទទួល:</u>**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

www.pheakdeylaw.com

# សញ្ញាសក្តិស្មារមេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់

ឧបសម្ព័ន្ធទី១ នៃអនុក្រឹត្យលេខ......
ចុះថ្ងៃទី...... ខែ...... ឆ្នាំ២០......
ស្តីពីសញ្ញាសក្តិ [illegible] មេឃុំ ចៅសង្កាត់ ជំទប់
ចៅសង្កាត់រង និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ។



មេឃុំ ចៅសង្កាត់



ជំទប់ ចៅសង្កាត់រង



សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់

www.pheakdeylaw.com

## ឯកសណ្ឋានការងាររបស់
## មេឃុំ ចៅសង្កាត់ជំទប់ ចៅសង្កាត់រង
## និង សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់

ភ្ជាប់ជាមួយប្រកាសលេខ ៦២ សហវ.ប្រក
ចុះថ្ងៃទី ០១ ខែមេសា ឆ្នាំ ២០១១
ស្តីពី ឯកសណ្ឋានការងាររបស់
មេឃុំ ចៅសង្កាត់ជំទប់ ចៅសង្កាត់រង និង
សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់



www.pheakdeylaw.com